**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

តុលាការខេត្តកំពង់ធំ
សំណុំរឿងព្រហ្មទណ្ឌ
លេខ ០៩ ចុះថ្ងៃទី ០៤
ខែ មករា ឆ្នាំ ២០០៦
សាលក្រម
លេខ ០៩ "ក" ចុះថ្ងៃទី ១០
ខែ កុម្ភៈ ឆ្នាំ ២០០៦

**គោរពនាមប្រជារាស្ត្រខ្មែរ**
**តុលាការខេត្តកំពង់ធំ**

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ បានបើកសវនាការជាសាធារណៈ នៅនាទីតុលាការខេត្តកំពង់ធំ នៅថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០០៦ ដោយមានសមាសភាពដូចតទៅ :

**ចៅក្រមជំនុំជំរះ**
លោក [redacted]
**តំណាងអយ្យការ**
លោក [redacted]
**ក្រឡាបញ្ជីសវនាការ**
លោក [redacted]

សាលក្រមនេះចូលស្ថាពរចាប់តាំងពីថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០០៦
តទៅដោយគូក្តីមិនចូលតវ៉ាតាមកំណត់ច្បាប់ ។
កំពង់ធំ,ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៦
**ប្រធានតុលាការខេត្ត**
[redacted]

**ដើម្បីជំនុំជំរះ :**

លើជនជាប់ចោទ ជនមិនស្គាល់មុខ " គ្មានសាវតារជាតិ " ។

ជាប់ចោទពីបទ : ធ្វើសន្និធិ ផលអនុផលព្រៃឈើ ដោយគ្មានការអនុញ្ញាតពីរដ្ឋបាលព្រៃឈើ ប្រព្រឹត្តនៅភូមិទំអរ ឃុំទីរីង ស្រុកសណ្តាន់ ខេត្តកំពង់ធំ កាលពីថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០០៥ ។

បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៩៦ កថាខណ្ឌទី១ ចំណុច០៣ នៃច្បាប់ស្តីពីព្រៃឈើ ។

-បានឃើញដីកាសន្និដ្ឋានចោទប្រកាន់ជូនរឿងទៅជំនុំជំរះផ្ទាល់លេខ : ០១ ចុះថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០០៦ របស់អយ្យការអមតុលាការខេត្តកំពង់ធំ ។

-បានឃើញដីកាចាត់តាំងចៅក្រមជំនុំជំរះលេខ : ២១ ចុះថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០០៦ របស់តុលាការខេត្តកំពង់ធំ ។

**ការប្រព្រឹត្តិរបស់ជនជាប់ចោទ**

កាលពីថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០០៥ សមត្ថកិច្ចសង្កាត់រដ្ឋបាលព្រៃឈើទីរីង បានចុះប្រតិបត្តិការប្រទះឃើញនៅចំណុចភូមិទំអរ ឃុំទីរីង ស្រុកសណ្តាន់ ខេត្តកំពង់ធំ ឃើញមានគំនរឈើហ៊ុបជ្រុងលេខ ០២ ចំនួន ៤៤ ដុំ ស្មើនឹង ៦.៩៤០ម៣ គ្មានអ្នកណាមកទទួលខុសត្រូវ ហើយសមត្ថកិច្ចបានយកឈើទាំងនោះមកប្រគល់ឱ្យលោក [redacted] ទទួលរក្សាទុកជាបណ្តោះអាសន្ន នៅសង្កាត់រដ្ឋបាលព្រៃឈើទីរីង ។



Scanned with CamScanner

-បានឃើញកំណត់ហេតុបទល្មើសជាក់ស្តែង ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០០៥ របស់សមត្ថកិច្ចសង្កាត់រដ្ឋបាលព្រៃឈើទីរីង បញ្ជាក់ថា :

១-កន្លែងកើតហេតុនៅចំណុចភូមិទំអរ ឃុំទីរីង ស្រុកសណ្តាន់ ខេត្តកំពង់ធំ

២-ប្រភេទបទល្មើសសន្និធិឈើហ៊ុបជ្រុងប្រភេទលេខ ០២ ដោយគ្មានលិខិតអនុញ្ញាតពីរដ្ឋបាលព្រៃឈើ

៣-វត្ថុតាងមាន ឈើហ៊ុបជ្រុងប្រភេទលេខ ០២ ចំនួន ៤៤ ដុំស្មើនឹង ៦.៥៨០ម៣

៤-ប្រព្រឹត្តដោយជនមិនស្គាល់មុខ

៥-នៅពេលត្រួតពិនិត្យមិនឃើញជនល្មើស

៦-បន្ទាប់ពីបានពិនិត្យជាក់ស្តែងឃើញថា ការធ្វើសន្និធិឈើហ៊ុបជ្រុងលេខ ០២ ខាងលើប្រាសចាកពីច្បាប់ស្តីពីព្រៃឈើ ហើយបានបញ្ជូនកំណត់ហេតុអំពើល្មើសជាក់ស្តែងនេះ ទៅសមត្ថកិច្ចថ្នាក់លើដើម្បីសំរេច ។

-បានឃើញកំណត់ហេតុនៃបទល្មើស ចុះថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០០៥ របស់នាយផ្នែករដ្ឋបាលព្រៃឈើទីរីង បានបញ្ជាក់ថា នៅថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០០៥ វេលាម៉ោង ១៣:៣០នាទី យើងបានទទួលរបាយការណ៍លេខ ៧២ សទពទ ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០០៥ ស្តីពីការចាប់ឃាត់ឈើហ៊ុបជ្រុងប្រភេទលេខ ០២ ចំនួន ៤៤ ដុំស្មើនឹង ៦.៥៨០ម៣ នៅចំណុចភូមិទំអរ ឃុំទីរីង ស្រុកសណ្តាន់ ខេត្តកំពង់ធំ ប្រព្រឹត្តដោយជនមិនស្គាល់មុខ ។ រីឯវត្ថុតាងត្រូវបានដឹកប្រគល់ឱ្យលោក ម្ចូ [redacted] ទទួលថែរក្សាបណ្តោះអាសន្ន ។

-បានឃើញលិខិតទទួលថែរក្សា ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០០៥ បញ្ជាក់ថា ឈ្មោះ **ម្ចូ គឹមឆេង** បានទទួលថែរក្សាវត្ថុតាងមានឈើហ៊ុបជ្រុងប្រភេទលេខ ០២ ចំនួន ៤៤ ដុំស្មើនឹង ៦.៥៨០ម៣ ។

## <u>នាះពេលសវនាការ</u>

លោក **អ៊ុន** [redacted] នាយរងសង្កាត់រដ្ឋបាលព្រៃឈើទីរីង ជាតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានឆ្លើយថា កាលពីថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០០៥ សមត្ថកិច្ចសង្កាត់រដ្ឋបាលព្រៃឈើទីរីង បានចុះប្រតិបត្តិការប្រទះឃើញនៅចំណុចភូមិទំអរ ឃុំទីរីង ស្រុកសណ្តាន់ ខេត្តកំពង់ធំ មានគំនរឈើហ៊ុបជ្រុងលេខ ០២ ចំនួន ៤៤ ដុំស្មើនឹង ៦.៥៨០ម៣ គ្មានអ្នកណាមកទទួលខុសត្រូវជាឈើរបស់ខ្លួនឡើយ សមត្ថកិច្ចក៏បានយកឈើទាំងនោះមករក្សាទុកជាបណ្តោះអាសន្ន នៅសង្កាត់រដ្ឋបាលព្រៃឈើទីរីង ដោយមានលោក ម្ចូ[redacted] ទទួលថែរក្សា ។ សំណូមពរតុលាការរឹបអូសវត្ថុតាង ជាប្រយោជន៍សម្បត្តិរដ្ឋ ។

តំណាងអយ្យការធ្វើសន្និដ្ឋានថា មានពិរុទ្ធភាពធ្ងន់ធ្ងរលើជនជាប់ចោទ ជនមិនស្គាល់មុខពីបទ : ធ្វើសន្និធិផលអនុផលព្រៃឈើ ដោយគ្មានលិខិតអនុញ្ញាតពីរដ្ឋបាលព្រៃឈើ ប្រព្រឹត្តនៅចំណុចភូមិទំអរ ឃុំទីរីង ស្រុកសណ្តាន់ ខេត្តកំពង់ធំ កាលពីថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០០៦ ។ ដូច្នេះអយ្យការសំរេចតំកល់ដីកាសន្និដ្ឋានចោទប្រកាន់ជូនរឿងជំនុំជំរះផ្ទាល់លេខ ០១ ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០៦ របស់អយ្យការទុកជាបានការពេញទាំងមូល សុំតុលាការសំរេចតាមច្បាប់ ។

-ក្រោយពីបានស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី



Scanned with CamScanner

-ក្រោយពីបានពិនិត្យភស្តុតាង
-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានទោសរបស់តំណាងអយ្យការ
-ក្រោយពីបានពិនិត្យត្រឹមត្រូវតាមច្បាប់ហើយ

**តុលាការខេត្តកំពង់ធំ**
**យល់ឃើញថា**

-កាលពីថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០០៥ សមត្ថកិច្ចសង្កាត់រដ្ឋបាលព្រៃឈើទីរីង បានចុះប្រតិបត្តិការប្រទះឃើញនៅចំណុចភូមិទំអរ ឃុំទីរីង ស្រុកសណ្តាន់ ខេត្តកំពង់ធំ មានគំនរឈើហ៊ុបជ្រុងលេខ ០២ ចំនួន ៤៤ ដុំស្មើនឹង ៦.៩៨០ម៉ែត្រ៣ គ្មានម្ចាស់ ហើយសមត្ថកិច្ចបានយកឈើទាំងនោះមកប្រគល់ឱ្យលោក ហូ គីមឆេង ទទួលថែរក្សាជាបណ្តោះអាសន្ន នៅសង្កាត់រដ្ឋបាលព្រៃឈើទីរីង ។
-ជនជាប់ចោទជាជនមិនស្គាល់មុខ "អញ្ញាតជន " គ្មានសាវតារជាតិ ។ ដូច្នេះតុលាការត្រូវសំរេចបង្គង់បណ្តឹងអាជ្ញាលើជនជាប់ចោទជាអញ្ញាតជននេះ ។
-សមត្ថកិច្ចរដ្ឋបាលព្រៃឈើបានប្រកាសស្រាវជ្រាវរកជនល្មើស ឱ្យបង្ហាញលិខិតអនុញ្ញាតក្នុងរយៈពេល ៣០ថ្ងៃ តាមកំណត់ច្បាប់ហើយ តែគ្មានជនណាម្នាក់ចេញមុខបង្ហាញលិខិតអនុញ្ញាតទេ ឃើញថាវត្ថុតាងនៃអំពើល្មើសច្បាប់ធ្វើសន្និធិផលព្រៃឈើ ដោយគ្មានលិខិតអនុញ្ញាត ដែលសមត្ថកិច្ចប្រមូលបានពីកន្លែងកើតហេតុ មានឈើហ៊ុបជ្រុងលេខ ០២ ចំនួន ៤៤ ដុំស្មើនឹង ៦.៩៨០ម៉ែត្រ៣ គឺជាឈើគ្មានម្ចាស់ ។ ដូច្នេះតុលាការត្រូវរឹបអូសឈើវត្ថុតាងទាំងអស់នេះ ជាប្រយោជន៍សម្បត្តិរដ្ឋតាមបញ្ញត្តិមាត្រា ៧៤ នៃច្បាប់ស្តីពីព្រៃឈើ ។

**ហេតុដូច្នេះតុលាការខេត្តកំពង់ធំ**
**វិនិច្ឆ័យសេចក្តី**

១-បង្គង់បណ្តឹងអាជ្ញាលើជនជាប់ចោទមិនស្គាល់មុខ "អញ្ញាតជន " គ្មានសាវតារជាតិ ពីបទ **ធ្វើសន្និធិផលព្រៃឈើ ដោយគ្មានលិខិតអនុញ្ញាតពីរដ្ឋបាលព្រៃឈើ** ប្រព្រឹត្តនៅភូមិទំអរ ឃុំទីរីង ស្រុកសណ្តាន់ ខេត្តកំពង់ធំ កាលពីថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០០៥ ។

២-សំរេចរឹបអូសវត្ថុតាងមាន ឈើហ៊ុបជ្រុងលេខ ០២ ចំនួន ៤៤ ដុំស្មើនឹងចំនួន ៦.៩៨០ម៉ែត្រ៣ ជាប្រយោជន៍សម្បត្តិរដ្ឋ ។

៣-សាលក្រមនេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខលោក អ៊ុន ប៊ុត្ត តំណាងដើមបណ្តឹងរដ្ឋប្បវេណី ទុកសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងរយៈពេល០២ខែ តាមកំណត់ច្បាប់ ។

**ចៅក្រមជំនុំជំរះ**
**ហត្ថលេខានិងត្រា**
[redacted]

**បានឃើញ**
**ប្រធានតុលាការខេត្ត**
[redacted]



Scanned with CamScanner